**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២១

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១**
**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូ កម្មវិធីZoom**

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា។*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ **"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២១"** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូ កម្មវិធីZoom ដោយសារតែការគំរាមកំហែងជាបន្តពីការឆ្លងរាតត្បាតនៃកូវីដ-១៩។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវឱ្យបន្តការប្រុងប្រយ័ត្នជាប់ជានិច្ច និងចូលរួមទប់ស្កាត់ការចម្លងទាំងអស់គ្នា ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់តាមការណែនាំរបស់រាជរដ្ឋាភិបាល និងបន្តអនុវត្តនូវវិធានបង្ការផ្សេងៗដាក់ចេញដោយក្រសួងសុខាភិបាល។

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គនាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការចូលរួម

ក៏ដូចជាការជំរុញឱ្យមានកិច្ចប្រជុំនានា ជាពិសេសកិច្ចប្រជុំស្តីពីការអនុវត្តន៍វិធានការ៦ចំណុចនៃ "លិខិតលេខ២១៣សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ឆ្ពោះទៅកាន់ចីរភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់រាជរដ្ឋាភិបាលកម្ពុជា។ ការងារនេះបាននិងកំពុងអនុវត្តបន្ត មានជាអាទិ៍៖ ការរៀបចំនូវវិធីសាស្ត្រ និងយន្តការនានាក្នុងការឆ្លើយតបនៅក្នុងបរិបទនៃការរាតត្បាតជំងឺកូវីដ-១៩ ក្នុងពេលកន្លងទៅថ្មីៗនេះ។ យើងក៏បាននិងកំពុងគិតគូរពីការកៀរគរថវិកាមួយចំនួន ទាំងថវិកាជាតិ និងគម្រោងមូលនិធិសកល ដើម្បីរៀបចំយុទ្ធសាស្ត្រប្រកបដោយភាពធន់ និងនវានុវត្តន៍ ក្នុងបរិបទនៃការរាលដាលជំងឺកូវីដ-១៩ ទៅលើការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ជាក់ស្តែង យើងទទួលបានលទ្ធផលជាផ្លែផ្កា ក្នុងការចរចាកញ្ចប់ថវិកាជាតិ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់រាជធានី ខេត្តចំនួន៤ ដែលត្រូវអនុវត្តគម្រោងកម្មវិធីទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ចាប់ពីឆ្នាំ២០២២ទៅ។ នេះជាសមិទ្ធផលថ្មីមួយទៀត នៅក្នុងការចូលរួមចំណែកក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចប់ការរីករាលដាលជំងឺអេដស៍ នៅឆ្នាំ២០២៥។ សម្រាប់ឆ្នាំ២០២៣ យើងនឹងបន្តចរចាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកញ្ចប់ថវិកាបន្ថែមសម្រាប់ខេត្តមួយចំនួនទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅថ្ងៃនេះ គឺជាកិច្ចប្រជុំលើកទី២ ក្នុងឆ្នាំ២០២១ ដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់រយៈពេល៦ខែចុងក្រោយ ដែលបានកំណត់ក្នុងសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី១ និងធ្វើការពិភាក្សាលើចំណុចខ្វះខាតមួយចំនួន ដែលទាមទារនូវដំណោះស្រាយ តាមរយៈការចូលរួមរបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមានក្នុងពេលនេះ។

តាមរបៀបវារៈ យើងនឹងមានបទបង្ហាញចំនួនពីរ ៖ បទបង្ហាញទី១ ស្តីពី "**ប្រព័ន្ធត្រួតពិនិត្យការអនុវត្តលិខិតលេខ២១៣សជណ.សស ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍**" ដែលរៀបចំដោយក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងបង្ហាញជូនដោយ **ឯកឧត្តម ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស ដើម្បីដាក់ឱ្យផ្សព្វផ្សាយ និងអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យការអនុវត្តលិខិតលេខ២១៣ស.ជ.ណ.សស ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ជាឧបករណ៍នៃការជំរុញតាមដានការ អនុវត្តន៍ សជណ ២១៣ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។ បទបង្ហាញទី២ ស្តីពី "**បញ្ចប់វិសមភាព បញ្ចប់អេដស៍ បញ្ចប់ជំងឺឆ្លងរាតត្បាតសកល**" ដែលនឹងបង្ហាញជូនដោយ**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ហើយជាចុងក្រោយ យើងនឹងធ្វើការអនុម័តទៅលើសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២១នេះផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍កិច្ចប្រជុំពេញអង្គថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ក្នុងការលុបបំបាត់ជំងឺអេដស៍ តាមរយៈការកំណត់យ៉ាងច្បាស់លាស់នូវគោលដៅសូន្យបី គឺ "គ្មានការឆ្លងមេរោគអេដស៍ថ្មី" "គ្មានការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍" និង "គ្មានការស្លាប់ដោយសារជំងឺអេដស៍" នៅត្រឹមឆ្នាំ២០២៥។ ដើម្បីសម្រេចបាននូវគោលដៅនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអំពាវនាវជាឱឡារិកដល់គ្រប់មជ្ឈដ្ឋានឱ្យរួមគ្នាជាចរន្តជាតិមួយដ៏ខ្លាំងក្លា ដែលនេះជាការប្តេជ្ញាចិត្តមួយដ៏រឹងមាំ និងជាកត្តាអនុគ្រោះចាំបាច់ប្រកបដោយប្រសិទ្ធភាពខ្ពស់រួចទៅហើយ។ ក្នុងន័យនេះ យើងបន្តជំរុញការចូលរួមជាពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ ដោយមានស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយជាពិសេស ដោយមានផែនការយុទ្ធសាស្រ្តជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តការអនុវត្តការងារឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នាពេលខាងមុខ ទៅតាមអនុសាសន៍ដែលនឹងទទួលបានពីកិច្ចប្រជុំពេញអង្គនាពេលនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ ពីបណ្តាសមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំតែត្រឹមនេះ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ មានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២១**" ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***